**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០១៤ គ.ជ.ប. ស.ន.៣

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ទាំង២៥ ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន **៨១៤ រូប** សម្រាប់បម្រើការងារនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ជំនួយការរដ្ឋបាល | ចំនួន ២៣ រូប |
| ២- ការីកុំព្យូទ័រ | ចំនួន ២៥ រូប |
| ៣- អ្នកយាម | ចំនួន ១០៤ រូប |
| ៤- អ្នកបើកបររថយន្ត | ចំនួន ២៧ រូប |
| ៥- គណនេយ្យករ | ចំនួន ២៥ រូប |
| ៦- បេឡាធិការ | ចំនួន ២៥ រូប |
| ៧- ជំនួយការគណនេយ្យ | ចំនួន ០៨ រូប |
| ៨- អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ | ចំនួន ២៥ រូប |
| ៩- មន្ត្រីប្រតិបត្តិការ និងភស្តុភារ | ចំនួន ៥៩ រូប |
| ១០- ជំនួយការកុំព្យូទ័រ | ចំនួន ២៥ រូប |
| ១១- ការីវិទ្យុទាក់ទង | ចំនួន ២៥ រូប |
| ១២- មន្ត្រីទទួល និងដោះស្រាយបណ្តឹង | ចំនួន ៣២ រូប |
| ១៣- ជំនួយការអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ (គ្រូបង្គោល) | ចំនួន ៤១១ រូប |

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្តីជូនដំណឹងនេះ។

- ការចាប់ផ្តើមទទួលពាក្យ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២៣
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

**ប្រាជ្ញ ចន្ទ**

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០១៩ គ.ជ.ប. ស.ន.៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី សម្រាប់បម្រើការងារ នៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ចំនួន ៨១៤រូប ឱ្យបម្រើការងារនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(លគធ.ខប) ទាំង២៥ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមានមុខតំណែងដូចខាងក្រោម ៖

| ល.រ | រាជធានី ខេត្ត | ជំនួយការរដ្ឋបាល | ការីកុំព្យូទ័រ | អ្នកយាម | អ្នកបើកបររថយន្ត | គណនេយ្យករ | បេឡាធិការ | ជំនួយការគណនេយ្យ | អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ | មន្ត្រីប្រតិបត្តិការនិងភស្តុភារ | ជំនួយការកុំព្យូទ័រ | ការីវិទ្យុទាក់ទង | មន្ត្រីទទួលនិងដោះស្រាយបណ្តឹង | គ្រូបង្ហាត់ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ១ | ១ | ៥ | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ១៨ | ៣៧ |
| ២ | បាត់ដំបង | ១ | ១ | ៦ | ១ | ១ | ១ | ១ | ១ | ២ | ១ | ១ | ២ | ៣០ | ៤៩ |
| ៣ | កំពង់ចាម | ១ | ១ | ៦ | ២ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ២០ | ៤១ |
| ៤ | កំពង់ឆ្នាំង | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១៦ | ៣០ |
| ៥ | កំពង់ស្ពឺ | X | ១ | ៤ | X | ១ | ១ | X | ១ | ៣ | ១ | ១ | ១ | ១៥ | ២៩ |
| ៦ | កំពង់ធំ | ១ | ១ | ៤ | ១ | ១ | ១ | X | ១ | ៣ | ១ | ១ | ២ | ១៨ | ៣៥ |
| ៧ | កំពត | ១ | ១ | ៤ | ១ | ១ | ១ | X | ១ | ៣ | ១ | ១ | ២ | ១៨ | ៣៥ |
| ៨ | កណ្តាល | ១ | ១ | ៦ | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ១ | ២១ | ៤០ |
| ៩ | កោះកុង | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១៤ | ២៨ |
| ១០ | ក្រចេះ | X | ១ | ២ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | X | ១៣ | ២៤ |
| ១១ | មណ្ឌលគិរី | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១២ | ២៦ |
| ១២ | ភ្នំពេញ | ១ | ១ | ៦ | ២ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ២៨ | ៤៩ |
| ១៣ | ព្រះវិហារ | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១៦ | ៣០ |
| ១៤ | ព្រៃវែង | ១ | ១ | ៦ | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ២៦ | ៤៦ |
| ១៥ | ពោធិ៍សាត់ | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១៤ | ២៨ |
| ១៦ | រតនគិរី | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១៨ | ៣២ |
| ១៧ | សៀមរាប | ១ | ១ | ៦ | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ២៤ | ៤៤ |
| ១៨ | ព្រះសីហនុ | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ១ | ១ | ១ | ១ | ១០ | ២៣ |
| ១៩ | ស្ទឹងត្រែង | ១ | ១ | ៣ | ២ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១២ | ២៧ |
| ២០ | ស្វាយរៀង | ១ | ១ | ៥ | ១ | ១ | ១ | X | ១ | ៣ | ១ | ១ | ១ | ១៦ | ៣៣ |

| ល.រ | រាជធានីខេត្ត | ជំនួយការរដ្ឋបាល | ការីកុំព្យូទ័រ | អ្នកយាម | អ្នកបើកបររថយន្ត | គណនេយ្យករ | បេឡាធិការ | ជំនួយការគណនេយ្យ | អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ | មន្ត្រីប្រតិបត្តិការនិងភស្តុភារ | ជំនួយការកុំព្យូទ័រ | ការីវិទ្យុទាក់ទង | មន្ត្រីទទួលនិងដោះស្រាយបណ្តឹង | ស្មៀនបង្កាត់ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២១ | តាកែវ | ១ | ១ | ៦ | ១ | ១ | ១ | ១ | ១ | ៣ | ១ | ១ | ២ | ២០ | ៤០ |
| ២២ | កែប | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ១ | ១ | ១ | X | ៤ | ១៦ |
| ២៣ | ប៉ៃលិន | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ១ | ១ | ១ | X | ៤ | ១៦ |
| ២៤ | ឧត្តរមានជ័យ | ១ | ១ | ៣ | ១ | ១ | ១ | X | ១ | ២ | ១ | ១ | ១ | ១០ | ២៤ |
| ២៥ | ត្បូងឃ្មុំ | ១ | ១ | ៥ | ១ | ១ | ១ | X | ១ | ៣ | ១ | ១ | ២ | ១៤ | ៣២ |
| | សរុប | ២៣ | ២៥ | ១០៤ | ២៧ | ២៥ | ២៥ | ៨ | ២៥ | ៥៩ | ២៥ | ២៥ | ៣២ | ៤១១ | ៨១៤ |

I- **លក្ខខណ្ឌទូទៅនៃបេក្ខជន ៖**

- មានសញ្ជាតិខ្មែរ និងមានអាយុតាមការកំណត់ក្នុងលក្ខខណ្ឌដោយឡែក
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសិទ្ធិបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដែលសាមីខ្លួនបានដាក់ពាក្យជាបេក្ខជន
- មានសុខភាពល្អ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក នៃខេត្តដែលពាក់ព័ន្ធនឹងការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ)
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែងគត់ ករណីឃើញថា បានដាក់ពាក្យលើសពីមួយមុខតំណែង ការដាក់ពាក្យនៅមុខតំណែងចុងក្រោយត្រូវសម្រេចយកជាផ្លូវការ
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត។

II - **លក្ខខណ្ឌបច្ចេកទេសដែលទាមទារដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ៖**

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានចំណេះដឹងទាក់ទងជាមួយមុខតំណែង
- សម្រាប់តួនាទីមួយចំនួនទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់។

III- **លក្ខខណ្ឌដោយឡែក ៖**

**១- ជំនួយការរដ្ឋបាល**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារទាក់ទងនឹងរដ្ឋបាល ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងការងាររដ្ឋបាល ៣ដងឡើងទៅ
- ចេះសរសេររបាយការណ៍ និងកំណត់ហេតុ

- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**២- ការីកុំព្យូទ័រ**

- មានអាយុយ៉ាងតិច ២១ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ៣ដងឡើងទៅ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១- QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

**៣- អ្នកយាម**

- មានអាយុយ៉ាងតិច ២០ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានបទពិសោធន៍ខាងការងារយាមល្បាត អគារ ឃ្លាំងចាប់ពី ២ឆ្នាំឡើងទៅ
- ចេះអាន ចេះសរសេរភាសាខ្មែរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងមួយមុខគឺធ្វើសម្ភាសន៍។

**៤- អ្នកបើកបររថយន្ត**

- មានអាយុយ៉ាងតិច ២២ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានប័ណ្ណបើកបររថយន្ត
- មានបទពិសោធន៍ក្នុងការងារបើកបរចាប់ពី ២ឆ្នាំឡើងទៅ
- ចេះអាន ចេះសរសេរភាសាខ្មែរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងមួយមុខគឺធ្វើសម្ភាសន៍។

**៥- គណនេយ្យករ**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារគណនេយ្យ និងហិរញ្ញវត្ថុចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងការងារគណនេយ្យ និងហិរញ្ញវត្ថុ ៣ដងឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៦- បេឡាធិការ**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬមានបទពិសោធន៍ការងារបេឡា ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងការងារបេឡា ៣ដងឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៧- ជំនួយការគណនេយ្យ**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារគណនេយ្យ និងហិរញ្ញវត្ថុ ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងការងារគណនេយ្យ និងហិរញ្ញវត្ថុ ៣ដងឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៨- អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងពាក់ព័ន្ធនឹងការងារចាត់ចែងគ្រប់គ្រងការងារស្តុក ឬមានបទពិសោធន៍ការងារគ្រប់គ្រងឃ្លាំងសម្ភារៈ និងការបែងចែកសម្ភារៈ ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតផ្នែកភស្តុភារ ៣ដងឡើងទៅ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.៥៦០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៩- មន្ត្រីប្រតិបត្តិការ និងភស្តុភារ**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងពាក់ព័ន្ធនឹងការងារប្រតិបត្តិការ និងភស្តុភារ ឬមានបទពិសោធន៍ការងារប្រតិបត្តិការ និងភស្តុភារចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតផ្នែកប្រតិបត្តិការ និងភស្តុភារ ៣ដងឡើងទៅ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**១០- ជំនួយការកុំព្យូទ័រ**

- មានអាយុយ៉ាងតិច ២៣ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ (ផ្នែកព័ត៌មានវិទ្យា) ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ៣ដងឡើងទៅ
- យល់ដឹងពីប្រព័ន្ធប្រតិបត្តិការ និង **Hardware Computer** ច្បាស់លាស់
- យល់ដឹងពីប្រព័ន្ធ **Network** (វិញ្ញាបនបត្រ ប្រសិនបើមាន)
- ចេះប្រើប្រាស់ **Internet** ស្ទាត់ជំនាញ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១- QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

**១១- ការីវិទ្យុទាក់ទង**

- មានអាយុយ៉ាងតិច ២០ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានបទពិសោធន៍ការងារវិទ្យុទាក់ទង ព្រមទាំងមានបទពិសោធន៍ការងារទំនាក់ទំនងព័ត៌មានច្បាស់លាស់ចាប់ពី ២ឆ្នាំឡើងទៅ
- មានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងមួយមុខគឺធ្វើសម្ភាសន៍។

**១២- មន្ត្រីទទួល និងដោះស្រាយបណ្ដឹង**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារច្បាប់ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងវិស័យច្បាប់ ៣ដងឡើងទៅ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**១៣- ជំនួយការអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ** (គ្រូបង្គោល)

**ក- គ្រូបង្គោលដែលអាចប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ (ត្រូវការ ១នាក់ ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបណ្ដុះបណ្ដាលចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធនឹងការងារបណ្ដុះបណ្ដាល ៣ដងឡើងទៅ
- ចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ និងចេះប្រើប្រាស់ **Internet** និង **Email**
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១- QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

**ខ- គ្រូបង្គោលផ្នែកទ្រឹស្ដី (ត្រូវការ ១នាក់ ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)**

- មានអាយុយ៉ាងតិច ២៥ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបណ្ដុះបណ្ដាលចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្ដុះបណ្ដាល ៣ដងឡើងទៅ (អាចប្រើប្រាស់កុំព្យូទ័របានកាន់តែប្រសើរ)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

## IV- **កាលបរិច្ឆេទចូលបម្រើការងារ**

ចាប់ផ្ដើមចូលបម្រើការងារពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

## V- **ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code លើសេចក្ដីជូនដំណឹងផ្សព្វផ្សាយ។

## VI- **កាលបរិច្ឆេទនៃការទទួលពាក្យប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍**

- ការចាប់ផ្ដើមទទួលពាក្យ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍ ចន្លោះពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣
- ការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។

VII- **ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

គណៈកម្មការរៀបចំការប្រឡង ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេ មកប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ។

VIII- **លទ្ធផលនៃការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍**

លទ្ធផលនៃការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍ នឹងបិទផ្សាយនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។

**<u>បញ្ជាក់បន្ថែម</u>** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល»
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃ សុក្រ ៥រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**